# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)

## សារណារបស់បណ្ឌិត Joanna Nicholson ក្នុងនាមជាអ្នកមិនមែនជាភាគី

## មិនគាំទ្រភាគីណា

## ដើម្បីប្រយោជន៍អ្នកមិនមែនជាភាគី

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 24-Jun-2016, 13:38
CMS/CFO: Sann Rada

បណ្ឌិត Joanna Nicholson គឺជាអ្នកស្រាវជ្រាវម្នាក់នៅផ្នែកពហុតុលាការ ដេប៉ាតឺម៉ង់ច្បាប់សាធារណៈ សាកលវិទ្យាល័យអូស្លូ ប្រទេសន័រវេ។ និក្ខេបបទបណ្ឌិតរបស់អ្នកស្រី គឺទាក់ទងនឹងយុទ្ធជន ជាជនរងគ្រោះនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ។ គាត់បង្រៀន និងសរសេរអំពីច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ច្បាប់មនុស្សធម៌អន្តរជាតិ ហើយមានចំណាប់អារម្មណ៍លើការវិវត្តដ៏ល្អនៅក្នុងវិស័យទាំងនេះ។

## សង្ខេបបញ្ហាចោទ

មាត្រា ៥ នៃច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចែងថា ដើម្បីឲ្យបទល្មើសណាមួយក្លាយជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ លុះត្រាតែបទល្មើសនោះត្រូវប្រព្រឹត្តឡើង ក្នុងនោះរួមមានបទល្មើសដែលជាផ្នែកមួយនៃការវាយប្រហារជាទូទៅ ឬជាប្រព័ន្ធមានគោលដៅជាចម្បងសំដៅលើ “ប្រជាជនស៊ីវិល”។ តាមច្បាប់ទម្លាប់អន្តរជាតិដែលចូលជាធរមាននៅចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នោះ តើការវាយប្រហាររបស់រដ្ឋ ឬ អង្គការមកលើសមាជិកនៃកងកម្លាំងប្រដាប់អាវុធ*ផ្ទាល់ខ្លួន* អាច ឬក៏មិនអាចជាការវាយប្រហារដែលសំដៅលើប្រជាជនស៊ីវិល បើយោងតាមគោលបំណងនៃមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក”។

## ទឡ្ហីករណ៍

**១. នៅក្នុងអំឡុងពេលសន្តិភាព បុគ្គលិកយោធា គឺជាផ្នែកមួយនៃប្រជាជនស៊ីវិល តាមគោលបំណងនៃលក្ខខណ្ឌតម្រូវទូទៅនៃមាត្រា ៥**

ខណៈដែលមានភាពខុសគ្នាផ្នែកឋានៈសង្គមរវាងសមាជិកយោធា និងជនស៊ីវិលនៅក្នុងអំឡុងពេលសន្តិភាព ប៉ុន្តែក៏មិនមានភាពខុសគ្នាផ្នែកច្បាប់ឡើយ[1]។ អាស្រ័យហេតុនេះ នៅក្នុងអំឡុងពេលសន្តិភាព បុគ្គលិកយោធា គឺជាជនស៊ីវិល និងជាផ្នែកមួយនៃប្រជាជនស៊ីវិល តាមគោលបំណងនៃលក្ខខណ្ឌតម្រូវទូទៅនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

## ២. នៅក្នុងអំឡុងពេលជម្លោះប្រដាប់អាវុធ មានភាពខុសគ្នារវាងបុគ្គលិកយោធាមិនមែនជាខ្លាំង ជាមួយនឹងជនស៊ីវិល តាមគោលបំណងនៃមាត្រា ៥

ប្រសិនបើជម្លោះប្រដាប់អាវុធណាមួយកំពុងតែកើតឡើង នោះត្រូវអនុវត្តច្បាប់មនុស្សធម៌អន្តរជាតិ។ ច្បាប់មនុស្សធម៌អន្តរជាតិ តម្រូវថា ត្រូវឲ្យមានភាពខុសគ្នារវាងយុទ្ធជន[2] ជាមួយនឹងជនស៊ីវិល។ ត្រូវមានកាតព្វកិច្ចដែលភាគីណាមួយនៅក្នុងជម្លោះត្រូវធ្វើការបែងចែកភាពខុសគ្នានេះ មិនមែនតែចំពោះកងកម្លាំងប្រដាប់អាវុធរបស់ខ្មាំង និងជនស៊ីវិលខ្មាំងប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវបែងចែករវាងកងកម្លាំងប្រដាប់អាវុធរបស់ខ្លួនឯងផ្ទាល់ ជាមួយនឹងប្រជាជនស៊ីវិលរបស់ខ្លួនឯងផ្ទាល់ផងដែរ។ ទោះបីជាច្បាប់មនុស្សធម៌អន្តរជាតិ ជាប់ពាក់ព័ន្ធជាចម្បងជាមួយនឹងកាតព្វកិច្ចរបស់រដ្ឋ ឬអង្គការមិនមែនជារដ្ឋដែលត្រូវប្រព្រឹត្តមកលើភាគីសត្រូវនៅក្នុងជម្លោះយ៉ាងណាក៏ដោយ ក៏ច្បាប់នេះដាក់កាតព្វកិច្ចចំពោះប្រជាជនស៊ីវិល[3] និងបុគ្គលិកយោធាផ្ទាល់ខ្លួនរបស់ភាគីនៅក្នុងជម្លោះដែរ[4]។

---

[1] មានទំនាក់ទំនងផ្នែកច្បាប់ខ្លះ។ ឧទាហរណ៍ តុលាការសិទ្ធិមនុស្សអឺរ៉ុប បានសម្រេចថា ការបកស្រាយ និងការអនុវត្តអនុសញ្ញាណសិទ្ធិមនុស្សអឺរ៉ុប អាចខុសគ្នានៅពេលដែលអនុវត្តចំពោះសមាជិកនៃកងកម្លាំងប្រដាប់អាវុធ ជាមួយនឹងជនស៊ីវិលនៅក្នុងអំឡុងពេលសន្តិភាព សូមមើល រឿងក្តី *Engel* តទល់នឹងហុល្លង់ (លេខ ១) (ឆ្នាំ ១៩៧៦) 1 ECtHR 647 កថាខណ្ឌ ៥៤ និងរឿងក្តី *Akbulut* តទល់នឹងទួគី ECtHR ពាក្យសុំលេខ ៤៥៦២៤/៩៩ សេចក្តីសម្រេចលើលទ្ធភាពទទួលពាក្យសុំ ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០០៣។

[2] ទស្សនាទានអំពីឋានៈយុទ្ធជន អនុវត្តតែនៅក្នុងជម្លោះប្រដាប់អាវុធអន្តរជាតិ(មាត្រា ៤៣ ពិធីសារបន្ថែម I) ប៉ុន្តែដើម្បីឲ្យច្បាស់ ទស្សនាទាននេះនឹងប្រើប្រាស់នៅទីនេះជាវិធីមួយដើម្បីពណ៌នាអំពីអ្នកដែលចូលរួមផ្ទាល់នៅក្នុងសកម្មភាពអរិភាពជាបន្តបន្ទាប់។

[3] ឧទាហរណ៍ កាតព្វកិច្ចត្រូវចាត់វិធានការបង្ការដើម្បីការពារជនស៊ីវិលពីផលប៉ះពាល់នៃការវាយប្រហារ គឺជាកាតព្វកិច្ចដែលត្រូវអនុវត្តចំពោះជនស៊ីវិលផ្ទាល់ខ្លួនរបស់ភាគីណាមួយ *សូមមើល* មាត្រា ៥៨ ពិធីសារបន្ថែម I ។

[4] បទប្បញ្ញត្តិមួយចំនួននៃច្បាប់មនុស្សធម៌អន្តរជាតិអនុវត្តចំពោះកងកម្លាំងផ្ទាល់ខ្លួនរបស់ភាគីណាមួយ។ នៅក្នុងជម្លោះប្រដាប់អាវុធអន្តរជាតិ វិធានការការពារអ្នករបួស អ្នកជំងឺ និងរបស់ខូចខាតអនុវត្តចំពោះជនគ្រប់រូបដោយមិនគិតពីញត្តិសម្ព័ន្ធ (អនុសញ្ញាទីក្រុងហ្សឺណែ I និង II) ហើយការធានាជាសារវ័ន្តមួយចំនួនក៏អនុវត្តបែបនេះដែរ (មាត្រា ៧៥ ពិធីសារបន្ថែម I)។ នៅក្នុងជម្លោះប្រដាប់អាវុធមិនមែនអន្តរជាតិ គឺអនុវត្តមាត្រា ៣ រួមនៃអនុសញ្ញាទីក្រុងហ្សឺណែវ ហើយផ្នែកផ្សេងៗនៃពិធីសារ

ឧទាហរណ៍ កាតព្វកិច្ចខ្លះនៅក្រោមច្បាប់មនុស្សធម៌អន្តរជាតិ គឺច្បាស់ជាយកមកអនុវត្តចំពោះតែបុគ្គលដែលជាប់ពាក់ព័ន្ធជាមួយនឹងភាគីបដិបក្សនៅក្នុងជម្លោះតែប៉ុណ្ណោះ គឺជនដែលត្រូវការពារនៅក្រោមអនុសញ្ញាទីក្រុងហ្សឺណែវទី ៤[5] និងឈ្លើយសឹក[6]។ បទប្បញ្ញត្តិផ្សេងទៀតនៅក្នុងច្បាប់មនុស្សធម៌អន្តរជាតិ មិនមានគុណវុឌ្ឍិបែបនេះឡើយ។ ឧទាហរណ៍ មាត្រា ៤៨ នៃពិធីសារបន្ថែម I ចែងថា "ភាគីនៅក្នុងជម្លោះ *គ្រប់ពេលទាំងអស់* ត្រូវបែងចែកឲ្យខុសគ្នារវាងប្រជាជនស៊ីវិល ជាមួយនឹងយុទ្ធជន"(គូសបញ្ជាក់បន្ថែម) ចំណែកឯ ពិធិសារបន្ថែម II ចែងថា "ប្រជាជនស៊ីវិល និងបុគ្គលជាជនស៊ីវិល ត្រូវទទួលបានការការពារជាទូទៅប្រឆាំងនឹងគ្រោះថ្នាក់ដែលកើតឡើងពីប្រតិបត្តិការយោធា"។ ហេតុនេះ កាតព្វកិច្ចដែលភាគីនៅក្នុងជម្លោះត្រូវបែងចែងឲ្យខុសគ្នារវាងជនស៊ីវិល ជាមួយនឹងយុទ្ធជន ក៏អនុវត្តផងដែរចំពោះកងកម្លាំងប្រដាប់អាវុធ និងប្រជាជនផ្ទាល់ខ្លួនរបស់ភាគីនោះ។ ហេតុនេះ បុគ្គលិកយោធាដែលមិនមែនជាអ្នកប្រឆាំងមិនចាំបាច់ថាត្រូវតែមានគុណវុឌ្ឍិឋានៈជាផ្នែកមួយនៃប្រជាជនស៊ីវិល តាមគោលបំណងនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងអំឡុងពេលជម្លោះប្រដាប់អាវុធឡើយ។

## ៣. ជនដែលបាត់បង់សមត្ថភាពប្រយុទ្ធ មិនមែនជាផ្នែកមួយនៃប្រជាជនស៊ីវិល ឡើយ ប៉ុន្តែអាចជាជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

មានភាពមិនច្បាស់លាស់ជុំវិញបញ្ហាថាតើ បុគ្គលិកយោធាដែលបាត់បង់សមត្ថភាពប្រយុទ្ធ អាចជាជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែរឬអត់។ បញ្ហាលំបាកនេះកើតឡើងដោយសារមានលក្ខខណ្ឌតម្រូវនៅក្នុងធាតុផ្សំទូទៅនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[7] ដែលបទល្មើសនីមួយៗប្រព្រឹត្តឡើងសំដៅលើ

---

បន្ថែម II ក៏អនុវត្តបែបនេះដែរ។ សម្រាប់ការពិភាក្សាលម្អិតថែមទៀត *សូមមើល* សារណារបស់ Joanna Nicholson ផ្នែក *តើឧក្រិដ្ឋកម្មសង្គ្រាមអាចប្រព្រឹត្តមកលើបុគ្គលយោធាដែលប្រឆាំងនឹងសមាជិកនៃកងកម្លាំងប្រដាប់អាវុធមិនមែនប្រឆាំងដែរឬទេ? សារណា ICD លេខ ១៦* ខែ ធ្នូ ឆ្នាំ ២០១៥ អាចចូលពិនិត្យមើលបានតាមរយៈ http://www.internationalcrimesdatabase.org/upload/documents/20151209T150352-Nicholoson%20ICD%20Format.pdf។

[5] មាត្រា ៤ អនុសញ្ញាទីក្រុងហ្សឺណែវ IV។

[6] មាត្រា ៤ ក អនុសញ្ញាទីក្រុងហ្សឺណែវ III និងមាត្រា ៤៤(១) ពិធីសារបន្ថែម I។

[7] ឧទាហរណ៍ មាត្រា ៥ នៃលក្ខន្តិកៈតុលការ ICTY។ មាត្រា ៣ នៃលក្ខន្តិកៈតុលាការ ICTR ។ មាត្រា ២ នៃលក្ខន្តិកៈតុលាការពិសេសសម្រាប់សេរ៉ាលីអូន។ មាត្រា ៧ នៃលក្ខន្តិកៈតុលការព្រហ្មទណ្ឌអន្តរជាតិ។ ប៉ុន្តែ សូមមើលសេចក្តីព្រាងនៃក្រមឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព និងសន្តិសុខមនុស្សជាតិ នៅក្នុង*សៀវភៅប្រចាំឆ្នាំរបស់គណៈកម្មការច្បាប់អន្តរជាតិ ឆ្នាំ ១៩៩១* វ៉ុល ១ កំណត់ហេតុសង្ខេបស្តីពីកិច្ចប្រជុំនៃសម័យប្រជុំលើកទី ៤៣ ថ្ងៃទី ២៩ ខែ មេសា ដល់ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩១ A/CN.4/SER.A/1991 ទំព័រ ២១៨-២២៣ ដែលមិនមានលក្ខខណ្ឌតម្រូវបែបនោះឡើយ។

"ប្រជជនស៊ីវិល"។ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់តតីតយូហ្គូស្លាវី (ICTY) និងតុលាការអន្តរជាតិសម្រាប់រ៉ាវ៉ាន់ដា (ICTR) បានប្រកាន់យកវិធីសាស្ត្រផ្សេងៗគ្នាចំពោះបញ្ហានេះ។

តុលាការ ICTY បានពិចារណាបញ្ហានេះជាច្រើនដង។ រឿងក្ដីខ្លះបានព្យាយាមរាប់បញ្ចូលជនដែលបាត់បង់សមត្ថភាពប្រយុទ្ធដាក់ក្នុងសញ្ញាណអំពីជនស៊ីវិល[8] ចំណែកឯរឿងក្ដីខ្លះទៀត បានព្យាយាមបញ្ចូលជនបែបនោះដាក់ក្នុងសញ្ញាណអំពីប្រជាជនស៊ីវិល[9]។ បញ្ហានេះបណ្ដាលឲ្យមានការភាន់ច្រឡំមួយចំនួននៅក្នុងយុត្តិសាស្ត្រនេះ។ ឧទាហរណ៍ នៅក្នុងរឿងក្ដី *Kordić និង Cerkez* អង្គជំនុំជម្រះតុលាការកំពូល យល់ឃើញថា ជនដែលបាត់បង់សមត្ថភាពប្រយុទ្ធ គឺជាជនស៊ីវិល។ អង្គជំនុំជម្រះនេះបានបញ្ជាក់ថា៖

> ទាហានត្រូវគេសម្លាប់បន្ទាប់ពីចាប់ខ្លួន បន្ទាប់ពីស្ថិតក្នុងស្ថានភាពបាត់បង់សមត្ថភាពប្រយុទ្ធ។ គ្មានមន្ទិលសង្ស័យឡើយ គឺថា ជនទាំងនេះដែលត្រូវកងកម្លាំងក្រូអាតសម្លាប់ដោយចេតនា គឺជា... "ជនស៊ីវិល"នៅក្នុងអត្ថន័យនៃមាត្រា ៥ នៃលក្ខន្តិកៈ...។ មិនមានមន្ទិលសង្ស័យឡើយគឺថា អំពើទាំងនេះក៏ជាផ្នែកមួយនៃការវាយប្រហារជាទូទៅដែលបានធ្វើឡើងនៅពេលនោះមកលើប្រជាជនស៊ីវិលអ៊ីស្លាម[10]។

រឿងក្ដីនេះអាចផ្ទុយពីរឿងក្ដី *Natalilić និង Martinović* ដែលជនមួយចំនួនក្នុងចំណោមជនដែលគេអះអាងថាជាជនរងគ្រោះ គឺជាឈ្លើយសឹក។ អង្គជំនុំជម្រះសាលាដំបូង បានពិចារណាលើសញ្ញាណអំពី "ប្រជាជនស៊ីវិល" ហើយបានសម្រេចថា "និយមន័យអំពីប្រជាជនស៊ីវិល រាប់បញ្ចូលទាំងបុគ្គលដែលនៅ

---

[8] ឧទាហរណ៍ *សូមមើល* រឿងក្ដី *រដ្ឋអាជ្ញាតទល់នឹង ZoranKupreškić និងអ្នកផ្សេងទៀត* តុលាការ ICTY, IT-95-16-T សាលក្រម ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០០ កថាខណ្ឌ ៥៤៧។ រឿងក្ដី *រដ្ឋអាជ្ញាតទល់នឹង Tihomir Blaškić,* តុលការ ICTY, IT-95-14-T, សាលក្រម ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ កថាខណ្ឌ ២១៤។ រឿងក្ដី *រដ្ឋអាជ្ញាតទល់នឹង Vidoje Blagojević និង Dragan Jokić* តុលាការ ICTY, IT-02-60-T, សាលក្រម ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ កថាខណ្ឌ ៥៤៤។

[9] រឿងក្ដី *រដ្ឋអាជ្ញាតទល់នឹង Goran Lelisić,* តុលាការ ICTY, IT-95-10-T, សាលក្រម ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ១៩៩៩ កថាខណ្ឌ ៥៤។

[10] រឿងក្ដី *រដ្ឋអាជ្ញាតទល់នឹង Dario Kordić និង Mario Cerkez* តុលាការ ICTY, IT-95-14/2-A, សាលដីកា ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៤ កថាខណ្ឌ ៤២១។

ពេលណាមួយអាចអនុវត្តសកម្មភាពតស៊ូប្រឆាំង និងជនដែលបាត់បង់សមត្ថភាពប្រយុទ្ធ”[11]។ អង្គជំនុំជម្រះក៏យល់ឃើញផងដែរថា ឈ្លើយសឹក គឺជាជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[12]។

បញ្ហានេះត្រូវបានពិចារណាយ៉ាងលម្អិតដោយអង្គជំនុំជម្រះតុលាការកំពូលរបស់ ICTY នៅក្នុងរឿងក្តីចំនួនពីរ គឺរឿងក្តី *Martić* និងរឿងក្តី *Mrškić*។ អង្គជំនុំជម្រះសាលាដំបូងនៅក្នុងរឿងទាំងពីរ បានសម្រេចថា បុគ្គលិកយោធាដែលបាត់បង់សមត្ថភាពប្រយុទ្ធ គឺមិនមែនជាជនស៊ីវិលឡើយតាមគោលបំណងនៃមាត្រា ៥ នៃលក្ខន្តិកៈតុលាការ ICTY[13]។ ការយល់ឃើញនេះត្រូវបានតម្កល់នៅពេលប្តឹងសារទុក្ខ[14]។ ប៉ុន្តែ នៅក្នុងរឿងក្តី *Martić* រដ្ឋអាជ្ញា បានដាក់សេចក្តីសន្និដ្ឋានលើកទីពីរ ដោយស្នើសុំតុលាការនេះ សម្រេចថាតើវាជាលក្ខខណ្ឌមួយក្នុងចំណោមលក្ខខណ្ឌទូទៅនៃមាត្រា ៥ ដែរឬអត់ដែលថា ដើម្បីក្លាយជាជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ជនរងគ្រោះត្រូវតែមានឋានៈជាជនស៊ីវិល និងថាតើ ជនដែលបាត់បង់សមត្ថភាពប្រយុទ្ធ ហើយមានវត្តមាននៅក្នុងចំណោមប្រជាជនស៊ីវិល ត្រូវដកចេញឋានៈជាជនរងគ្រោះនៃឧក្រិដ្ឋកម្មនេះដែរឬអត់[15]។

អង្គជំនុំជម្រះតុលាការកំពូលនៅក្នុងរឿងក្តី *Martić* បានសម្រេចថា លក្ខខណ្ឌទូទៅនេះមិនតម្រូវថា អំពើឧក្រិដ្ឋកម្មនីមួយៗត្រូវប្រព្រឹត្តមកលើជនស៊ីវិលឡើយ ប៉ុន្តែ លក្ខខណ្ឌនេះមានបំណងសង្កត់ធ្ងន់លើលក្ខណៈសមូហភាពនៃឧក្រិដ្ឋកម្ម។ ដរាបណាលក្ខខណ្ឌទូទៅនេះត្រូវបានបំពេញ ហើយមានការវាយប្រហារជាទូទៅ និងជាប្រព័ន្ធមកលើប្រជាជនស៊ីវិល ពេលនោះ បុគ្គលជាជនរងគ្រោះដែលបាត់បង់សមត្ថភាពប្រយុទ្ធ អាចជាជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[16]។ នេះត្រូវបានគេសម្រេចថាជាច្បាប់ទម្លាប់អន្តរជាតិនៅពេលប្រព្រឹត្តបទល្មើសទាំងនោះនៅពេលនោះ។

---

[11] រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Mladen Naletilić និង Vinko Martinović* តុលាការ ICTY, IT-98-34-T, សាលក្រម ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៣ កថាខណ្ឌ ២៣៥។

[12] ដូចជើងទំព័រខាងលើ កថាខណ្ឌ ៣៩២។

[13] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Martić,*តុលាការ ICTY, IT-95-11-T សាលក្រម ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៧ កថាខណ្ឌ ៥៦។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Mile Mršksić និងអ្នកផ្សេងទៀត,* តុលាការ ICTY, IT-95-13/1-T សាលក្រម ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៧ កថាខណ្ឌ ៤៥៩-៤៦៣ និងកថាខណ្ឌ ៤៨១។

[14] រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Martić,* IT-95-11-A សាលដីកា ថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០០៨ កថាខណ្ឌ ២៩៧ និង ៣០២ និង រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Mile Mršksić និងអ្នកផ្សេងទៀត,* IT-95-13/1-A សាលដីកា ថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០០៩។

[15] រឿងក្តី *Martić* ដូចជើងទំព័រខាងលើ កថាខណ្ឌ ៣០៣។

[16] រឿងក្តី *Martić* ដូចជើងទំព័រ ១៤ ខាងលើ កថាខណ្ឌ ៣០៣-៣១៤។

វិធីសាស្ត្រនេះទទួលបានការឯកភាពនៅក្នុងសាលដីកាសំណុំរឿង *Mrškić*។ អង្គជំនុំជម្រះតុលាការកំពូល បានឯកភាពគ្នាសម្រេចថា តាមលក្ខណៈទូទៅនៃមាត្រា៥ មិនមានលក្ខខណ្ឌតម្រូវដែលថា បុគ្គលជាជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវតែជាជនស៊ីវិលនោះឡើយ ដរាបណា មានការបង្ហាញថា ការវាយប្រហារជាទូទៅ ឬជាប្រព័ន្ធ គឺសំដៅលើប្រជាជនស៊ីវិល ហើយបានសម្រេចទៀតថា មានចំណងពាក់ព័ន្ធរវាងអំពើទាំងនោះជាមួយនឹងការវាយប្រហារ ហើយជនចាប់ចោទ បានដឹងថា អំពើរបស់គាត់ មានការជាប់ពាក់ព័ន្ធបែបនោះ[17]។ អង្គជំនុំជម្រះនេះបានយល់ឃើញថា ឋានៈជាជនស៊ីវិលរបស់ជនរងគ្រោះ ចំនួនជនស៊ីវិល និងសមាមាត្រជនរងគ្រោះក្នុងចំណោមប្រជាជនស៊ីវិល គឺមានសារៈសំខាន់នៅពេលដែលកំណត់ថាតើធាតុផ្សំទូទៅនេះបានបំពេញឬអត់[18]។

វិធីសាស្ត្ររបស់តុលាការ ICTY ត្រូវបានតុលាការពិសេសសម្រាប់សេរ៉ាលីអូន អនុវត្តតាម។ នៅក្នុងរឿងក្តី *RUF* អង្គជំនុំជម្រះសាលាដំបូង បានបញ្ជាក់ថា៖

> នៅក្នុងរឿងក្តី *Martić* អង្គជំនុំជម្រះ យល់ស្របតាមអង្គជំនុំជម្រះតុលាការកំពូលរបស់ ICTY ថា ក្នុងករណីដែលជនណាម្នាក់បាត់បង់សមត្ថភាពប្រយុទ្ធ គឺជាជនរងគ្រោះនៃអំពើមួយដែលសត្យានុម័តជាផ្នែកមួយនៃការវាយប្រហារកាន់តែទូទៅសំដៅលើប្រជាជនស៊ីវិលនោះ អំពើនេះអាចស្មើនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[19]។

តុលាការនេះបានយល់ឃើញថា ការសម្លាប់ទាហានដែលបាត់បង់សមត្ថភាពប្រយុទ្ធ បង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[20]។ បញ្ហានេះមិនទាន់បានពិចារណាដោយតុលាការ ICC នៅឡើយទេ។

វិធីសាស្ត្ររបស់តុលាការ ICTR ចំពោះបញ្ហានេះ ខុសគ្នាពីវិធីសាស្ត្ររបស់តុលាការ ICTY។ តុលាការ ICTR យល់ឃើញថា ជនដែលបាត់បង់សមត្ថភាពប្រយុទ្ធ គឺជាផ្នែកមួយនៃប្រជាជនស៊ីវិល។ នៅក្នុងរឿងក្តី *Akayesu* អង្គជំនុំជម្រះសាលាដំបូង បានបញ្ជាក់ថា៖

---

[17] រឿងក្តី *Mršksić* ដូចជើងទំព័រ ១៤ ខាងលើ កថាខណ្ឌ ៣៣។

[18] ដូចជើងទំព័រខាងលើ កថាខណ្ឌ ៣០-៣២។

[19] រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Issa Hassan Sesay, Morris Kallon និង Augustine Gbao,* SCSL-2004-15-T សាលក្រម ថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០០៩ កថាខណ្ឌ ៣២។

[20] ដូចជើងទំព័រខាងលើ កថាខណ្ឌ ១៤៤៨។

> សមាជិកនៃប្រជាជនស៊ីវិល គឺជាមនុស្សដែលមិនចូលរួមយ៉ាងសកម្មនៅក្នុងសកម្មភាពអរិភាព រួមមាន សមាជិកនៃកងកម្លាំងប្រដាប់អាវុធដែលបានទម្លាក់អាវុធ និងជនដែលស្ថិតក្នុងសភាពបាត់បង់សមត្ថភាពប្រយុទ្ធ ដោយសារជំងឺ របួស ការឃុំខ្លួន ឬមូលហេតុណាផ្សេងទៀត[21]។

និយមន័យនេះអំពីប្រជាជនស៊ីវិល ត្រូវបានតុលាការ ICTR អនុវត្តជាបន្តបន្ទាប់នៅក្នុងរឿងក្តីជាបន្តបន្ទាប់ ហើយមិនបានក្លាយជាកម្មវត្ថុនៃការជំទាស់តវ៉ាឡើយ[22]។

ហេតុនេះ សាលាក្តីពិសេសទាំងនេះយល់ស្របថា ជនដែលបាត់បង់សមត្ថភាពប្រយុទ្ធ អាចជាជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ប៉ុន្តែ វិធីសាស្ត្ររបស់សាលាក្តីទាំងនេះមានភាពខុសគ្នាចំពោះមូលហេតុនៃការយល់ស្របរបស់ខ្លួន។ តុលាការ ICTY បានសម្រេចថា ជនដែលបាត់បង់សមត្ថភាពប្រយុទ្ធ មិនមែនជាជនស៊ីវិលតាមគោលបំណងនៃមាត្រា៥ នៃលក្ខន្តិកៈរបស់ខ្លួនឡើយ ហើយជនបែបនោះក៏មិនមែនជាផ្នែកមួយនៃប្រជាជនស៊ីវិលដែរ។ ប៉ុន្តែ ពួកគេអាចជាជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដរាបណាមានការវាយប្រហារសំដៅលើប្រជាជនស៊ីវិល ហើយមានចំណងពាក់ព័ន្ធរវាងការវាយប្រហារនេះជាមួយនឹងបទល្មើសដែលបានប្រព្រឹត្តឡើងមកលើជនដែលបាត់បង់សមត្ថភាពប្រយុទ្ធ។ ផ្ទុយមកវិញ តុលាការ ICTR បានសម្រេចថា ជនដែលបាត់បង់សមត្ថភាពប្រយុទ្ធ គឺជាផ្នែកមួយនៃប្រជាជនស៊ីវិល។

វិធីសាស្ត្រខុសគ្នាទាំងនេះមានចំណងពាក់ព័ន្ធគ្នាសំខាន់ៗ។ នៅតុលាការ ICTY ការវាយប្រហារតែមកលើជនបាត់បង់សមត្ថភាពប្រយុទ្ធ មិនមានគុណវុឌ្ឍិជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ ពីព្រោះថាជនទាំងនោះមិនមែនជាផ្នែកមួយនៃប្រជាជនស៊ីវិល ហើយមិនមានចំណងពាក់ព័ន្ធរវាងការវាយប្រហារនោះជាមួយនឹងការវាយប្រហារកាន់តែទូទៅមកលើប្រជាជនស៊ីវិល[23]។ តាមពិត នេះច្បាស់ជាអ្វីដែលបានកើត

---

[21] រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Jean-Paul Akayesu,* ICTR-96-4-T សាលក្រម ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៨ កថាខណ្ឌ ៥៨២។

[22] ឧទាហរណ៍ រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង George Anderson Nderubumwe Rutaganda,* ICTR-96-3-T សាលក្រម ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ១៩៩៩ កថាខណ្ឌ ៧១។ រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Paul Bisengimana,* ICTR-00-60-T សាលក្រម ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០០៦ កថាខណ្ឌ ៤៨-៥១។ រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Athanase Seromba,* ICTR-2001-66-I សាលក្រម ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៦ កថាខណ្ឌ ៣៥៨។ រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Jean de Dieu Kamuhanda,* ICTR-95-54A-T សាលក្រម ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០៤ កថាខណ្ឌ ៦៦៧។ រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Juvénal Kajelijeli,* ICTR-98-44A-T សាលក្រម ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៣ កថាខណ្ឌ ៨៧៣-៨៧៤ និងរឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Alfred Musema,* ICTR-96-13-A សាលក្រម ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០០៦ កថាខណ្ឌ ២០៧។

[23] រឿងក្តី *Mrškić* ដូចជើងទំព័រ ១៤ ខាងលើ កថាខណ្ឌ ៤២-៤៤។

ឡើងនៅក្នុងរឿងក្តី *Mrškić* ដែលពាក់ព័ន្ធនឹងបុគ្គលឃោធាដែលជាប់ឃុំខ្លួន។ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា ជនរងគ្រោះទាំងនោះមិនអាចជាជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ ពីព្រោះថា ពួកគេត្រូវបានគេយកជាគោលដៅដោយសារពួកគេជាសមាជិកនៃកងកម្លាំងប្រដាប់អាវុធក្រអាត ហើយមិនមានចំណងពាក់ព័ន្ធរវាងការវាយប្រហារមកលើពួកគេ ជាមួយនឹងការវាយប្រហារមកលើប្រជាជនស៊ីវិលឡើយ។ ជនរងគ្រោះដែលគេបានអះអាងទាំងនេះអាចជាជនរងគ្រោះនៃឧក្រិដ្ឋកម្មសង្គ្រាមតែប៉ុណ្ណោះ[24]។ ប្រសិនបើអនុវត្តវិធីសាស្ត្ររបស់តុលាការ ICTR វិញ នឹងមានន័យថា ការវាយប្រហារបែបនេះបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ពីព្រោះថា ជនដែលបាត់បង់សមត្ថភាពប្រយុទ្ធ គឺជាផ្នែកមួយនៃ ប្រជាជនស៊ីវិល។

ក្នុងចំណោមវិធីសាស្ត្រទាំងពីរនេះ វិធីសាស្ត្ររបស់តុលាការ ICTY ត្រូវបានពិចារណាលម្អិតជាង ហើយមានការអះអាងថា នេះគឺជាអ្វីដែល អ.វ.ត.ក គួរប្រកាន់យក។ ប្រសិនបើជនដែលបាត់បង់សមត្ថភាពប្រយុទ្ធ មិនមែនជាជនស៊ីវិល ដូចដែលតុលាការ ICTY និង អ.វ.ត.ក បានសម្រេចនោះ វាមិនសមហេតុផលថា ជនបែបនោះអាចជាផ្នែកមួយនៃប្រជាជនស៊ីវិលឡើយ។

## ៤. នេះគឺជាជំហរនៅក្នុងច្បាប់ទម្លាប់អន្តរជាតិនៅចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩

ការណ៍ដែលថា ជនបាត់បង់សមត្ថភាពប្រយុទ្ធ អាចជាជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិប្រព្រឹត្តឡើងដោយបុគ្គលដែលមិនមែនជាសត្រូវនោះ គឺជាច្បាប់ទម្លាប់អន្តរជាតិនៅចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩។ បញ្ហានេះបានដោះស្រាយនៅក្នុងរឿងក្តីនានាចាប់តាំងពីពេលក្រោយសម័យសង្គ្រាមលោកលើកទី ២។ នៅក្នុងរឿងក្តី *P និងអ្នកផ្សេងទៀត*[25] តុលាការកំពូលអាល្លឺម៉ង់ នៅភូមិភាគកាន់កាប់ដោយចក្រភពអង់គ្លេស ដោយអនុវត្តមាត្រា II (១)(គ)នៃច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ ១០ បានពិចារណាថាតើ ការសម្លាប់ក្រុមកងម៉ារីនអាល្លឺម៉ង់ បង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែរឬអត់។ ក្រុមកងម៉ារីននេះត្រូវបានចាប់ខ្លួននៅពេលដែលព្យាយាមគេចពីប្រទេសដាណឺម៉ាក ត្រឡប់ទៅអាល្លឺម៉ង់ វិញ មុនពេលអាល្លឺម៉ង់ ចុះចាញ់។ ក្នុងករណីនេះ មនុស្សបីនាក់ត្រូវបានតុលាការយោធាអាល្លឺម៉ង់ កាត់ទោសប្រហារជីវិតដោយសាររត់ចោលជួរ ហើយត្រូវបានប្រហារជីវិតតាមពេលវេលាសមស្រប។ តុលាការកំពូលនេះបានរកឃើញថា សមាជិកនៃតុលាការយោធានេះមានទោសពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ពីព្រោះថា

---

[24] ដូចជើងទំព័រខាងលើ ។

[25] រឿងក្តី *P និងអ្នកផ្សេងទៀត* ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ១៩៤៨ Entscheidgunge des Obersten Gerichtshofes für die Britische Zone in Strafsachen, St S 111/48។

ការដាក់ទោសដែលខ្លួនបានដាក់មកលើសមាជិកកងម៉ារីនទាំងនោះគឺហួសហេតុបើប្រៀបធៀបជាមួយនឹងទម្ងន់នៃបទឧក្រិដ្ឋនោះហើយការដាក់ទោសនេះគឺជាការបង្ហាញយ៉ាងច្បាស់ពីរបបព្រៃផ្សៃរបស់ណាហ្ស៊ីស[26] ។

បញ្ហានេះបានកើតឡើងម្តងទៀតនៅចំពោះមុខតុលាការកំពូលអាល្លឺម៉ង់នៅក្នុងរឿងក្តី *H* ។ រឿងក្តីនេះពាក់ព័ន្ធនឹងទង្វើរបស់ចៅក្រមអាល្លឺម៉ង់មួយរូបដែលធ្វើជាប្រធានជំនុំជម្រះនៅក្នុងរឿងក្តីចោទមន្ត្រីពីរនាក់នៅកងនាវាអាល្លឺម៉ង់។ មន្ត្រីអាល្លឺម៉ង់ម្នាក់ រងការចោទប្រកាន់ពីបទរិះគន់អ៊ីត្លែរ ចំណែកឯម្នាក់ទៀតរងការចោទប្រកាន់ពីបទទទួលបានអត្តសញ្ញាណបណ្ណបរទេសសម្រាប់ខ្លួនគាត់ និងប្រពន្ធគាត់។ ចៅក្រមរូបនោះបានកាត់ទោសប្រហារជីវិតមន្ត្រីទាំងពីរនាក់នេះ។ តុលាការកំពូលអាល្លឺម៉ង់ បានផ្តន្ទាទោសចៅក្រមរូបនោះពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ការកាត់ទោសហួសហេតុមកលើមន្ត្រីអាល្លឺម៉ង់ទាំងពីរខាងលើត្រូវបានគេរកឃើញថាជាផ្នែកមួយនៃប្រព័ន្ធព្រៃផ្សៃរបស់ណាហ្ស៊ីស[27]។

មានការយល់ឃើញផ្សេងមួយនៅក្នុងរឿងក្តី *Pilz* នៅចំពោះមុខតុលាការជាន់ខ្ពស់ពិសេសរបស់ហូល្លង់[28]។ រឿងក្តីនេះពាក់ព័ន្ធនឹងថាតើទាហានម្នាក់នៅក្នុងជួរកងទ័ពអាល្លឺម៉ង់ដែលចូលកាន់កាប់ អាចជាជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែរឬអត់។ វេជ្ជបណ្ឌិតម្នាក់នៅក្នុងជួរកងទ័ពអាល្លឺម៉ង់ រងការចោទប្រកាន់ថាបានបញ្ជា ឬក៏អនុញ្ញាតឲ្យអ្នកក្រោមបង្គាប់ បាញ់ទាហាននោះឲ្យរបួស ហើយក្រោយមក មិនព្រមឲ្យគាត់ទទួលបានជំនួយវេជ្ជសាស្ត្រឡើយ ធ្វើឲ្យទាហាននោះស្លាប់។ តុលាការនេះបានសម្រេចថា បទល្មើសនេះមិនអាចចាត់ទុកថាជាឧក្រិដ្ឋកម្មសង្គ្រាមបានឡើយ ប៉ុន្តែក៏មិនអាចបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបានដែរ ពីព្រោះថា៖

> ជនរងគ្រោះនេះមិនមែនជាផ្នែកមួយនៃប្រជាជនស៊ីវិលនៅលើដែនដីដែលគេកាន់កាប់ឡើយ ហើយអំពើដែលគេចោទគាត់ ក៏មិន(អាច)ចាត់ទុកថាជាផ្នែកមួយនៃប្រព័ន្ធធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនាឡើយ[29]។

---

[26] ដូចជើងទំព័រខាងលើ ទំព័រ ២២៨-២២៩។

[27] រឿងក្តី *H* ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩៤៩ Entscheidgunge des Obersten Gerichtshofes für die Britische Zone in Strafsachen, St S 309/49។

[28] *Pilz* យុត្តិសាស្ត្រហូល្លង់ ឆ្នាំ ១៩៥០ លេខ ៦៨១ ត្រង់ ១២១០-២១១។ និង*របាយការណ៍ច្បាប់អន្តរជាតិ* ឆ្នាំ ១៩៥០ ទំព័រ ៣៩១-៣៩២ និងសូមមើល Cassese ដូចខាងលើ *** ទំព័រ ៤៦៦។

[29] ដូចដកស្រង់នៅ Cassese ដូចខាងលើ *** ទំព័រ ៤៦៦ ជើងទំព័រ ២៧។

លទ្ធផលនៃរឿងក្ដីនេះ អាចពន្យល់បានតាមរយៈអង្គហេតុដែលថា នៅពេលត្រឹមនេះ អ្នកខ្លះបានជឿថា មានភាពខុសគ្នារវាងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិប្រភេទធ្វើទុក្ខបុកម្នេញ ជាមួយនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិប្រភេទធ្វើមនុស្សឃាត[30] ហើយបុគ្គលិកយោធា អាចត្រឹមជាជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សប្រភេទធ្វើមនុស្សឃាត តែប៉ុណ្ណោះ។ រឿងក្ដីនេះហាក់ដូចជាយល់ស្របតាមការជំនឿនោះ។ ប៉ុន្តែ ក្នុងចំណោមរឿងក្ដីមួយក្ដាប់តូចដែលបានពិចារណាបញ្ហានេះ រឿងក្ដីនេះគ្រាន់តែជារឿងក្ដីតែមួយគត់ដែលធ្វើឲ្យមានភាពខុសគ្នាបែបនេះ[31]។

## សេចក្ដីសន្និដ្ឋាន

សមាជិកនៃកងកម្លាំងដែលមិនមែនជាអ្នកប្រឆាំង អាចជាជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ នៅក្នុងអំឡុងពេលសន្តិភាព សមាជិកបែបនេះគឺជាផ្នែកមួយនៃប្រជាជនស៊ីវិល តាមគោលបំណងនៃលក្ខខណ្ឌតម្រូវទូទៅនៃមាត្រា ៥។ នៅក្នុងអំឡុងពេលមានជម្លោះប្រដាប់អាវុធ ភាពខុសគ្នារវាងយុទ្ធជនជាមួយនឹងជនស៊ីវិល ក៏អនុវត្តផងដែរចំពោះប្រជាជនដែលមិនមែនជាសត្រូវ។ សមាជិកនៃកងកម្លាំងដែលមិនមែនជាសត្រូវ គឺមិនមែនជាផ្នែកមួយនៃប្រជាជនស៊ីវិលឡើយ ប៉ុន្តែអាចជាជនរងគ្រោះនៃឧក្រិដ្ឋកម្មនេះដូចគ្នានឹងសមាជិកនៃកងកម្លាំងសត្រូវដែរ ប្រសិនបើការវាយប្រហារមកលើពួកគេគឺជាផ្នែកមួយនៃការវាយប្រហារកាន់តែទូទៅមកលើប្រជាជនស៊ីវិល ហើយមានចំណងពាក់ព័ន្ធគ្នារវាងការវាយប្រហារទាំងពីរនេះ។ បន្ថែមពីលើនេះទៀត នេះគឺជាគោលជំហរនៅក្នុងច្បាប់ទំនៀមទម្លាប់នៅក្នុងរយៈកាលពីចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩។

---

[30] Antonio Cassese "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ៖ មតិយោបល់ស្ដីពីចំណុចបញ្ហាខ្លះ នៅក្នុងឯកសារ Antonio Casses, ផ្នែកមនុស្សនៃច្បាប់អន្តរជាតិ សារណាសម្រិតសម្រាំង សារព័ត៌មានសាកលវិទ្យាល័យអុកស្វឺដ ឆ្នាំ ២០០៨) ទំព័រ ៤៦៥-៤៧១។ គណៈកម្មការឧក្រិដ្ឋកម្មសង្គ្រាមអង្គការសហប្រជាជាតិ *ប្រវត្តិគណៈកម្មការឧក្រិដ្ឋកម្មសង្គ្រាមអង្គការសហប្រជាជាតិ និងការបង្កើតច្បាប់ស្ដីពីសង្គ្រាម* (ទីក្រុងឡុងដ៍, HMSO, ឆ្នាំ ១៩៤៨) ទំព័រ ១៩៣។ មិនមែនគ្រប់គ្នាបានយល់ស្របតាមភាពខុសគ្នានេះឡើយ *សូមមើល* Egon Schwelb "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" *សៀវភៅចក្រភពអង់គ្លេសស្ដីពីច្បាប់អន្តរជាតិ* វ៉ុល ២៣ លេខ ១៧៨ (ឆ្នាំ ១៩៤៦) ទំព័រ ១៩០។

[31] បន្ថែមពីលើរឿងក្ដីខាងលើ *សូមមើល* រឿងក្ដី RuSHA ដែលបានសម្រេចថា ឈ្លើយសឹកគឺជាជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

សូមទទួលនូវការគោរពដ៏ជ្រាលជ្រៅអំពីខ្ញុំ។

បណ្ឌិត Joanna Nichoson

ទីក្រុងអូស្លូ ថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០១៦